# សេចក្តីសង្គ្រោះនិងការសន្យារបស់ព្រះជាម្ចាស់

Salvation and the Promises of God

ឧបមាថាមានអ្នកអធិប្បាយម្នាក់បានមកអធិប្បាយព្រះបន្ទូលនៅពួកជំនុំរបស់អ្នក។ គាត់បានបង្រៀនថា ព្រះយេស៊ូវបានលេចមកឱ្យគាត់ឃើញហើយបានបើកសំដែងព្រះបន្ទូលនេះដល់គាត់ ដែលគាត់នឹងចែកចាយបន្តិចទៀតនោះ។ គាត់បាននិយាយយ៉ាងនេះទៀតថា ព្រះយេស៊ូវបាន ប្រាប់គាត់ថា ប្រសិនបើអ្នកណាបដិសេធន៍នូវព្រះបន្ទូលដែលគាត់ចែកចាយនេះ អ្នកនោះនឹងមាន ទោសស្ថិតក្រោមការវិនិច្ឆ័យរបស់ព្រះ។ គាត់បានអធិប្បាយយ៉ាងនេះថា ព្រះជាម្ចាស់ទ្រង់ប្រកប ដោយអំណាចនិងក្តីស្រឡាញ់ ទ្រង់ស្រឡាញ់ដល់កូនរបស់ទ្រង់គ្រប់គ្នាហើយទ្រង់ក៏សព្វព្រះទ័យឱ្យយើង រាល់គ្នាក្លាយទៅជាអ្នកមានដែរ។ គាត់អធិប្បាយយ៉ាងនេះទៀតថា ប្រសិនបើយើងមានជំនឿពិត នោះយើងអាចសូមឱ្យទ្រង់ប្រោសយើងឱ្យបានជាសះស្បើយ ពីគ្រប់ទាំង ជំងឺរោគាផ្សេងៗ ហើយទ្រង់នឹងធ្វើឱ្យយើងមានសុខភាពល្អផង។ តែប្រសិនបើយើងមិនបានទទួល ការប្រោសឱ្យជា ឬមិនបានទទួលនូវសុខភាពល្អនោះមានន័យថា យើងខ្វះជំនឿ ឬយើងមានលាក់បំពួននូវ អំពើបាបនៅក្នុងជីវិតហើយ។ ចំពោះអ្នកវិញ តើអ្នកយល់ព្រម ឬមិនយល់ព្រមចំពោះសេចក្តីបង្រៀន នេះ? ហេតុអ្វី?

នៅពេលដែលខ្ញុំសួរគ្រីស្ទបរិស័ទពីទំនាក់ទំនងរវាងសេចក្តីសង្គ្រោះរបស់យើង និងសេចក្តីសន្យា របស់ព្រះជាម្ចាស់ អ្នកទាំងនោះតែងតែសំឡឹងមើលមកខ្ញុំទាំងទឹកមុខងឿងឆ្ងល់ ដែលនោះបញ្ជាក់ថា ពួកគេមិនទាន់ដឹងប្រាកដនៅឡើយថា ទាំងពីរយ៉ាងមានទំនាក់ទំនងស្អិតជាមួយគ្នា ឬក៏បង្ហាញថាមិនដែលមានអ្នកណាធ្លាប់បង្រៀនពួកគេពីបញ្ហានេះដែរ។ ប៉ុន្តែ តាមរយៈព្រះគម្ពីរបរិសុទ្ធ ការដែល ដឹងថាសេចក្តីសង្គ្រោះរបស់យើងអាស្រ័យទៅលើសេចក្តីសន្យារបស់ទ្រង់ នោះជារឿងមួយសំខាន់។

## *តើយើងអាចទទួលបានសេចក្តីសន្យាដោយរបៀបណា?*

***សង្ខេប*** សេចក្តីសន្យារបស់ព្រះជាម្ចាស់មកតាមរយៈព្រះគ្រីស្ទ

ឃ្លាថា "នៅក្នុងព្រះគ្រីស្ទ" ព្រះគម្ពីរសញ្ញាថ្មីបានប្រើជាង១០០ដង។ គេប្រើពាក្យនេះដើម្បីបញ្ជាក់ ឬ សង្កត់ធ្ងន់ពីសេចក្តីពិតមួយថា គ្រប់ទាំងអស់ដែលយើងបានទទួលពីព្រះអង្គនៅពេលទ្រង់សង្គ្រោះយើង នោះយើងបានទទួលនៅក្នុងព្រះគ្រីស្ទ។ គ្រប់ទាំងសេចក្តីសន្យាដែលព្រះប្រទានដល់យើងគឺទ្រង់ ប្រទានតាមរយៈអង្គព្រះគ្រីស្ទ។ ដូច្នេះហើយបានជាលោកប៉ុលបានសរសេរនៅក្នុង ២កូរិន. ១:២០ ថា "*ដ្បិតទោះបីមានសេចក្តីសន្យារបស់ព្រះយ៉ាងណាក៏ដោយ ក៏នៅសុទ្ធតែជា "បាទ" នៅក្នុង ទ្រង់...*"។ ឯនៅក្នុងព្រះគម្ពីរអេភេសូរជំពូកមួយលោកប៉ុលបានរៀបរាប់ពីព្រះពរដែលយើងអាចទទួលបាននៅក្នុងព្រះគ្រីស្ទ។ លោកចាប់ផ្តើមរៀបរាប់ពីព្រះពរនេះដោយដំបូងឡើយ លោកមានប្រសាសន៍ថា "សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានប្រទានពរមកយើងក្នុងព្រះគ្រីស្ទដោយគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់" (ខ៣)។ ចូរកំណត់ចំណាំនៅក្នុងខនេះលោកបានប្រើពាក្យ "នៅក្នុងព្រះគ្រីស្ទ" សារជាថ្មីម្តងទៀត។ ដូច្នេះមានន័យថា គ្រប់ទាំងព្រះពរដែលគ្រីស្ទបរិស័ទបានទទួលមកនៅក្នុងសេចក្តីសង្គ្រោះ គឺមកតាមរយៈ ព្រះគ្រីស្ទតែមួយគត់។

ដោយហេតុនេះហើយបានជាគេតែងនិយាយថា នៅលើពិភពលោកនេះមានមនុស្ស២ប្រភេទ ប្រភេទ ទី១ គឺអស់ពួកអ្នកដែលនៅក្រៅព្រះគ្រីស្ទ ហើយទី២ គឺអស់ពួកអ្នកដែលនៅក្នុងព្រះគ្រីស្ទ។ អស់អ្នក ដែលនៅក្រៅព្រះគ្រីស្ទគឺជាពួកមនុស្សចំឡែកនៅចំពោះព្រះជាម្ចាស់ ហើយពួកនេះនឹងមិនបានទទួលព្រះពរដែលមកដោយសារសេចក្តីសង្គ្រោះតាមរយៈ

អង្គព្រះគ្រីស្ទនោះទេ។ ប៉ុន្តែអស់អ្នកដែលនៅក្នុងព្រះគ្រីស្ទវិញ គឺជាពួក អ្នកដែលអាចទទួលគ្រប់ទាំងព្រះពរពីព្រះជាម្ចាស់ ដែលទ្រង់បានប្រទានមកតាមរយៈ អង្គព្រះគ្រីស្ទ។

## *តើយើងត្រូវធ្វើអ្វីខ្លះដើម្បីទទួលបាននូវសេចក្តីសន្យានេះ?*

***សង្ខេប*** ដើម្បីទទួលបាននូវសេចក្តីសន្យានេះ យើងត្រូវតែស្តាប់ឮព្រះបន្ទូលនៃសេចក្តីសន្យានោះ (គឺដំណឹងល្អ) ហើយជឿជាក់ថា ព្រះជាម្ចាស់នឹងធ្វើនូវអ្វីដែលទ្រង់បានសន្យា។

នៅក្នុងកណ្ឌគម្ពីររ៉ូម ៤:១-៥ លោកប៉ុលបានលើកយកលោកអ័ប្រាហាំមកធ្វើជាឲ្យឧទាហរណ៍ ពីគំរូពីរបៀបដែលយើងគួរឆ្លើយតបទៅចំពោះសេចក្តីសន្យារបស់ព្រះជាម្ចាស់។ នៅក្នុងអត្ថបទនេះ លោកប៉ុលបាននិយាយសំដៅទៅលើព្រឹត្តិការណ៍ដែលមាននៅក្នុងលោកុប្បត្តិ. ១៥ គឺជាព្រឹត្តិការណ៍មួយ ស្តីពីសេចក្តីសន្យារបស់ព្រះជាម្ចាស់ចំពោះលោកអ័ប្រាហាំ ដោយទ្រង់បានសន្យាថាលោកនឹងបានគ្រងមរតក ហើយលោកនឹងមានកូនចៅយ៉ាងសន្ធឹកដូចខ្សាច់នៅមាត់សមុទ្រដែលមិនអាចរាប់បាននោះផង។ ពេលនោះអ័ប្រាហាំជឿលើសេចក្តីសន្យារបស់ព្រះ។ <u>ចូរធ្វើការកត់សំគាល់កន្លែងនេះបន្តិច</u> ព្រះជាម្ចាស់បានផ្តើមធ្វើអន្តរកម្មជាមួយនឹងលោកអ័ប្រាហាំដោយទ្រង់បានផ្តើមធ្វើសេចក្តីសន្យាមួយជាមួយនឹងលោក។ បន្ទាប់ពីបានស្តាប់ឮអន្តរកម្មនៃសេចក្តីសន្យារបស់ព្រះ លោកអ័ប្រាហាំមបានឆ្លើយតបទៅចំ ពោះការនោះដោយព្រមជឿជាក់លើសេចក្តីសន្យានោះ (រ៉ូម ៤:១៦, ២០-២១)។

នៅក្នុងសញ្ញាថ្មីព្រះជាម្ចាស់ក៏បានធ្វើការសន្យារបស់ព្រះអង្គដែរហើយសេចក្តីសន្យានោះមកតាមរយៈអង្គព្រះគ្រីស្ទ។ អ័ប្រាហាំបានឆ្លើយតបយ៉ាងត្រឹមត្រូវទៅចំពោះសេចក្តីសន្យារបស់ព្រះ គឺដោយជឿថាទ្រង់នឹងធ្វើអ្វីៗដែលទ្រង់បានសន្យានោះយើងក៏ត្រូវឆ្លើយតបតាមរបៀប ត្រឹមត្រូវយ៉ាងនោះដែរ ដោយជឿជាក់ ថា ព្រះអង្គនឹងធ្វើអ្វីៗដែលទ្រង់បានសន្យាដែរតាមរយៈអង្គព្រះគ្រីស្ទ។

ចូរចាំថា ជំនឿ មិនមែនត្រឹមតែជឿថា មានព្រះប៉ុណ្ណោះទេ ប៉ុន្តែគឺទុកចិត្តលើសេចក្តីសន្យារបស់ព្រះ។ ដូច្នេះសេចក្តីសន្យារបស់ព្រះតាមរយៈអង្គព្រះគ្រីស្ទគឺជាគ្រឹះនៃសេចក្តីជំនឿរបស់គ្រីស្ទបរិស័ទគ្រប់រូប។ ប្រសិនបើអ្នកណាមិនដែលបានស្តាប់ឮសេចក្តីសន្យារបស់ព្រះតាមរយៈព្រះយេស៊ូវគ្រីស្ទ (គឺដំណឹងល្អ) នោះទេ នោះគេក៏មិនអាចមានជំនឿឡើយ។ ហេតុនេះហើយបានជាលោកប៉ុលបានលើកឡើងថា "*បើគេមិនជឿ ធ្វើដូចម្តេចឱ្យគេអំពាវនាវដល់ព្រះបាន? ហើយបើគេមិនបានឮនិយាយ នោះធ្វើដូចម្តេចឱ្យគេ ជឿដល់ព្រះបាន? ហើយ ធ្វើដូចម្តេចឱ្យគេឮបានបើគ្មានអ្នកណាប្រាប់សោះ? មួយទៀត ធ្វើដូចម្តេចឱ្យមានអ្នកណាប្រាប់បាន លើកតែមានអ្នកណាចាត់ឱ្យគេទៅ? ដូចជាមានសេចក្តីចែងទុកមកថា "ជើងនៃពួកអ្នក ដែលប្រកាស ប្រាប់ដំណឹងល្អ ពីសេចក្តីសុខសាន្ត ហើយថ្លែងប្រាប់ពីសេចក្តីដែលបណ្តាលឱ្យរីករាយចិត្ត នោះល្អប្រពៃយ៉ាងណាហ្ន៎*" (រ៉ូម ១០:១៤-១៥)។

> ជំនឿ មិនមែនត្រឹមតែជឿថា មានព្រះប៉ុណ្ណោះទេ ប៉ុន្តែគឺទុកចិត្តលើសេចក្តីសន្យារបស់ព្រះ។ ដូច្នេះសេចក្តីសន្យារបស់ព្រះតាមរយៈអង្គព្រះគ្រីស្ទ(គឺដំណឹងល្អ) គឺជាគ្រឹះនៃសេចក្តីជំនឿរបស់គ្រីស្ទបរិស័ទ។

## *សារៈសំខាន់ចំពោះការស្គាល់នូវអ្វីដែលព្រះបានសន្យា*

***សង្ខេប*** ការពិចារណាពីអ្វីដែលបានសន្យា គឺជារឿងមួយដែលមានសារៈសំខាន់បំផុតនៅពេលដែលយើងធ្វើការវិភាគនូវសេចក្តីបង្រៀនរបស់ពួកអ្នកដែលថា គ្រីស្ទបរិស័ទ គួរតែមានទ្រព្យសម្បត្តិស្តុកស្តម្ភ ឬគួរតែជាអ្នកមាន និងប្រកបដោយសុខភាពល្អនៅក្នុងជីវិតនេះ។

សញ្ញាថ្មីតែងហៅសេចក្តីសន្យាទាំងឡាយដែលមាននៅក្នុងព្រះគ្រីស្ទថាជាដំណឹងល្អ។ ដំណឹងល្អនោះគឺថា ព្រះយេស៊ូវគ្រីស្ទជាមួយអង្គដែលយាងមកសំរេចគ្រប់ទាំងសេចក្តីសន្យារបស់ព្រះជាម្ចាស់។ តើព្រះជាម្ចាស់បានសន្យាអ្វីខ្លះនៅក្នុងដំណឹងល្អ? យើងអាចមើលឃើញបញ្ជីរាយនាមនៃការតាំងសញ្ញាថ្មីនៅក្នុងកណ្ឌគម្ពីរ យេរេមា ៣១:៣១-៣៤។ សេចក្តីសន្យាទាំងអស់នេះគឺជាសេចក្តីសន្យាដ៏សំខាន់ដែលយើងអាចទទួលបានក្នុងព្រះគ្រីស្ទ។ យើងអាចមើលឃើញមានបញ្ជីរាយនាមនៃសេចក្តីសន្យាមួយទៀតនៅក្នុង កណ្ឌគម្ពីរអេភេសូរ ១:៣-១៤។ អត្ថបទនេះបានចែងសង្កត់ធ្ងន់ថា យើងបានទទួលការប្រោសលោះ ការអត់ទោសបាប រួចហើយ ហើយព្រះពរទាំងពីរយ៉ាងនេះយើងអាចទទួលបាននៅក្នុងព្រះគ្រីស្ទ (ខ៧)។

សព្វថ្ងៃនេះមានការអធិប្បាយជាច្រើនដែលគេឱ្យឈ្មោះថា ដំណឹងល្អពីសុខភាពនិងទ្រព្យសម្បត្តិ។ សេចក្តីអធិប្បាយរបស់អ្នកខ្លះដែលអធិប្បាយដំណឹងល្អពីសុខភាពនិងទ្រព្យសម្បត្តិបង្រៀនថា ជានិច្ច ជាកាលយើងគួរតែសូមសម្បត្តិទ្រព្យពីព្រះជាម្ចាស់។ ប្រសិនបើសេចក្តីសំណូមរបស់យើងមិនកើតការនោះជាសញ្ញាបង្ហាញថា យើងខ្វះជំនឿ ឬយើងមានបាបលាក់ទុកក្នុងជីវិតហើយ។ សេចក្តីបង្រៀននេះអាចបង្ករឱ្យមានគ្រោះយ៉ាងថ្នាក់ធ្ងន់ធ្ងរ ដល់គ្រីស្ទាន និងដល់ពួកជំនុំ។ ចលនាមួយដែល បង្រៀនពីសេចក្តីទាំងនេះមានឈ្មោះថា ចលនា ពាក្យនៃសេចក្តីជំនឿ។ ចលនានេះចាប់ផ្តើមបង្រៀនដំបូងនៅសហរដ្ឋអាមេរិក។ ពួកគ្រូដែលបង្រៀននៅក្នុងក្រុមនេះ រួមមាន លោកខេននីតហាហ្គីន លោកខេននីតខូពលែន នាងម៉ារីលីន ហីកឃី (គាត់គឺជាម្នាក់ដែលគេបានអញ្ជើញមក អធិប្បាយនៅក្នុងពិធីតាំង ពិពណ៌គ្រីស្ទបរិស័ទលើកទី១នៅកម្ពុជា) និងមានគ្រូផ្សេងៗជាច្រើនទៀត។

## *តើទ្រព្យសម្បត្តិ និងសុខភាពនៅក្នុងជីវិតនេះគឺជាអ្វីដែលព្រះបានសន្យាមែនឬ?*

***សង្ខេប*** ព្រះជាម្ចាស់អាចប្រោសឱ្យជា ហើយសព្វថ្ងៃនេះទ្រង់ពិតជាប្រោសមនុស្សខ្លះឱ្យជាមែន ប៉ុន្តែសុខភាពនិងទ្រព្យសម្បត្តិនៅក្នុងជីវិតនេះ មិនមែនជាអ្វីដែលព្រះជាម្ចាស់បានសន្យានោះទេ ដូច្នេះសេចក្តីបង្រៀនដែលនិយាយថានោះគឺជាអ្វីដែលព្រះជាម្ចាស់បានសន្យា គឺកំពុងតែប្រកាសសេចក្តីសន្យាខុសឆ្គង ហើយកំពុង តែប្រកាសដំណឹងល្អខុសឆ្គងដែរ

ពេលដែលយើងគិតដល់សេចក្តីបង្រៀននេះ ការសំខាន់ណាស់ដែលយើងត្រូវនឹកចាំពីនូវសំនួរមួយ ដែលសួរថា តើទ្រព្យសម្បត្តិនិងសុខភាពនៅក្នុងជីវិតនេះគឺជាអ្វីដែលព្រះជាម្ចាស់បានសន្យាឬ? នេះ គឺជា ចំនុចសំខាន់ដែលត្រូវលើកយកមកវិភាគ។ ជាធម្មតាអស់ពួកអ្នកដែលបង្រៀន ដំណឹងល្អ សុខភាពនិងទ្រព្យសម្បត្តិ តែងអះអាងថា ព្រះជាម្ចាស់ពិតជាបានសន្យាសេចក្តីទាំងពីរយ៉ាងនេះមែន។ ពួកអ្នកទាំង នោះអាចប្រើពាក្យផ្សេងៗដើម្បីធ្វើការ "សន្យា" ដូចជាពាក្យថា "សិទ្ធិ"ជាដើម។ ក្រុមគ្រូបង្រៀននៅក្នុងក្រុម*ពាក្យនៃជំនឿ* បង្រៀនថាគ្រីស្ទបរិស័ទត្រូវតែស្គាល់ពី "អត្តសញ្ញាណ" របស់ខ្លួនយើងនៅក្នុងព្រះគ្រីស្ទ យើងត្រូវស្គាល់ពី "សិទ្ធិ" របស់យើងនៅក្នុងទ្រង់ដែរ។ យើងមាន "សិទ្ធិ" នៅក្នុងព្រះគ្រីស្ទដើម្បីថ្លែង ប្រាប់ពីសុខភាពនិងទ្រព្យសម្បត្តិ ថ្លែងប្រកាសពីការផ្គត់ផ្គង់ របស់ព្រះគ្រីស្ទសំរាប់គ្រប់ទាំងតំរូវការ និងបញ្ហាផ្សេងៗនៅក្នុងជីវិត។ អ្វីដែលយើងត្រូវធ្វើ គឺយើងគ្រាន់តែប្រើមាត់របស់យើង "សារភាព" ថាអ្វីៗដែលយើងទទួលបាន ជា "សិទ្ធិ" របស់យើង នោះយើងនឹងទទួលបាននូវអ្វីដែលយើងចង់បាន មិនខាន។ ពួក *ពាក្យនៃជំនឿ* បានបង្រៀនថា ការប្រោសលោះរបស់ព្រះយេស៊ូវគ្រីស្ទ នាំមកនូវការ ប្រោសឱ្យជា ដូច្នេះ គ្រីស្ទបរិស័ទពិតប្រាកដ អ្នកជឿពិតប្រាកដ នឹងមិនដែលឈឺឡើយ។

មានវិធីមួយទៀតដែលពួកគេបង្រៀនពីដំណឹងល្អនៃសុខភាព និងទ្រព្យសម្បត្តិដោយពួកគេពោល អះអាងថា ព្រះជាម្ចាស់ទ្រង់ល្អទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ទ្រង់ចង់ឱ្យយើងរស់នៅក្នុងជីវិត សប្បាយរីករាយ ហេតុនេះវាប្រាកដណាស់ប្រសិនបើយើងសូមទ្រង់ដោយជំនឿនោះទ្រង់នឹងប្រទាន សុខភាពនិងទ្រព្យសម្បត្តិដល់យើងមិនខាន។ ពួកគេបាននិយាយថា ការប្រោសឱ្យជាគឺជាបំណង ព្រះហឫទ័យ របស់ព្រះជាម្ចាស់ ដូច្នេះប្រសិនបើអ្នកមិនបានទទួលការប្រោសឱ្យជាទេ នោះ

បង្ហាញយ៉ាងច្បាស់ថា អ្នកនឹងមិននៅក្នុងព្រះហរទ័យរបស់ព្រះទេ។ ជានិច្ចកាលជំងឺរោគាព្យាធិផ្សេងៗ កើតឡើងដោយសារតែ ការមិនជឿ ឬអំពើបាប ឬទាំងពីរយ៉ាង។

ជារឿយៗ ពួកអ្នកដែលបង្រៀនសេចក្តីទាំងនេះ តែងដកស្រង់យកខគម្ពីរផ្សេងៗមកគាំទ្រគោលជំហរ នៃសេចក្តីបង្រៀនរបស់ពួកគេ។ ពួកគេអាចស្រង់យកខគម្ពីរជាច្រើននៅសញ្ញាចាស់មកបង្ហាញប្រាប់ ពីកន្លែងដែលព្រះជាម្ចាស់បានសន្យាប្រទានសុខភាព និងទ្រព្យសម្បត្តិដល់ពួកអ៊ីស្រាអែល។ ប៉ុន្តែចូរ កត់សំគាល់ត្រង់នេះឱ្យបានច្បាស់ថា មិនមានសេចក្តីសន្យាណាមួយក្នុងចំណោមសេចក្តីសន្យាទាំងអស់នោះដែលទ្រង់បានសន្យាថា នឹងប្រទានដល់គ្រីស្ទាននៅក្នុងសម័យនេះដែរនោះទេ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីមានខគម្ពីរខ្លះៗដែលពួកគេទាំងនោះអាចស្រង់យកមកធ្វើជាអំណះអំណាងរបស់ពួកគេដែរ ដូចជា កណ្ឌគម្ពីរយ៉ាកុប ៥:១៤-១៥ លោកយ៉ាកុបបានមានប្រសាសន៍ថា "តើមានពួកអ្នករាល់គ្នា ណាមួយឈឺឬទេ? ត្រូវឱ្យអ្នកនោះហៅពួកចាស់ទុំក្នុងពួកជំនុំមកអធិស្ឋានឱ្យចុះ ព្រមទាំងលាបប្រេងឱ្យ ដោយនូវព្រះនាមព្រះអម្ចាស់ផង នោះពាក្យអធិស្ឋាននៃសេចក្តីជំនឿនិងជួយសង្គ្រោះដល់មនុស្សហេវ នោះ ហើយព្រះអម្ចាស់ទ្រង់នឹងប្រោសឱ្យគាត់បានជាឡើង បើគាត់បានធ្វើបាបអ្វី នោះនឹងបានអត់ ទោសឱ្យផង"។

ប្រសិនបើយើងចូលទៅលំអិតនៅក្នុងខព្រះគម្ពីរនេះ នោះវាហាក់ដូចជាវែងបន្តិច តែឥឡូវនេះ យើង នឹងធ្វើការសង្កេតពីរយ៉ាងទៅលើខនេះ។ ជាញឹកញយ ពេលដែលអ្នកជឿនៅក្នុងព្រះគម្ពីរ ធ្លាក់ខ្លួនឈឺ គេមិនដែលនិយាយ ឬស្តីបន្ទោសដល់អ្នកជំងឺនោះថា នេះដោយសាតែអ្នកឯងខ្វះជំនឿ ឬដោយសាតែ អំពើបាបបានជាអ្នកឯងឈឺយ៉ាងនេះនោះទេ (យ៉ូប, ២កូរិន . ១២:៧-៩, កាឡាទី ៤:១៣-១៥, ភីលីព ៣:២៥-២៧, ១ធីម៉ូថេ ៥:២៣, ២ធីម៉ូថេ ៤:២០)។ ប៉ុន្តែ នៅពេលដែលអ្នកជឿនៅក្នុងព្រះគម្ពីរ ធ្លាក់ខ្លួនឈឺ យើងត្រូវសួរថាហេតុអ្វីបានជាព្រះមិនប្រោសអ្នកជំងឺនោះ ហើយហេតុអ្វី បានជាការនេះក៏កើតមានឡើងដល់គ្រីស្ទានសព្វថ្ងៃនេះដែរ? ហេតុផលដ៏ច្បាស់លាស់ មួយនោះ គឺពីព្រោះ ការប្រោសឱ្យជាពីជំងឺរោគាព្យាធិផ្សេងៗក្នុងជីវិតនេះ មិនមែនជាសេចក្តីសន្យារបស់ព្រះជាម្ចាស់នោះទេ ហើយនៅក្នុងដំណឹងល្អ ព្រះអង្គក៏មិនបានសន្យា ការប្រោសឱ្យជានេះដែរ។ ជាការពិត ទ្រង់អាចនឹងប្រោសយើងឱ្យជាពីជំងឺរោគាផ្សេងៗ ហើយនៅក្នុងពួកជំនុំ យើងអាចអធិស្ឋានឱ្យគ្នាទៅវិញទៅមកដើម្បីឱ្យបានជាពីជំងឺដែលមាន។ ប៉ុន្តែត្រូវចាំថា ព្រះមិនចាំបាច់ ត្រូវតែ ប្រោសយើងឱ្យជានោះទេ ព្រោះនោះមិនមែនជាសេចក្តីសន្យារបស់ព្រះជាម្ចាស់ទេ។ យើងអាចទទួល បានការអត់ទោសបាបពីទ្រង់ យើងអាចទទួលបាននូវជីវិតថ្មី ចិត្តគំនិតថ្មី យើងអាចស្គាល់ព្រះអង្គ និង ដឹងថាទ្រង់បានទទួលយើងទុកដូចជាកូនចិញ្ចឹមរបស់ទ្រង់ យើងអាចទទួលបានការទាំងអស់នោះដោយ សានោះគឺជាអ្វីដែលទ្រង់បានសន្យាតាមរយៈដំណឹងល្អ។

លើសពីនេះទៅទៀត យើងតែងសង្កេតឃើញយ៉ាងនេះវិញថា អ្នកជឿនៅក្នុងព្រះគម្ពីរ សញ្ញាថ្មី តែងពើបប្រទះ បញ្ហាផ្សេងៗនៅក្នុងជីវិត និងមានជីវភាពក្រីក្រ។ ជាធម្មតាទុក្ខលំបាករបស់គ្រីស្ទាន ចេះតែមានចំនួនច្រើនឡើង គឺច្រើនជាងមុនពេលដែលពួកគេជឿព្រះអង្គទៅទៀតដោយសារតែ ភក្តីភាពរបស់ពួកគេទៅចំពោះព្រះយេស៊ូវគ្រីស្ទ។ ការត្រាស់ហៅឱ្យបានដើរតាមអង្គព្រះយេស៊ូវ គ្រីស្ទ គឺជាការត្រាស់ហៅម្យ៉ាងតំរូវឱ្យលះកាត់ចិត្តខ្លួនឯង ហើយលីឈើឆ្កាងដើរតាមព្រះអង្គ។

សរុបមក ក្នុងនាមជាអ្នកបំរើដំណឹងល្អដ៏បរិសុទ្ធរបស់ព្រះយេស៊ូវគ្រីស្ទ យើងត្រូវតែបដិសេធន៍ ដាច់ខាតនូវសេចក្តីបង្រៀនរបស់ចលនា *ពាក្យនៃជំនឿ* ដ្បិតនោះគឺជាដំណឹងល្អខុសឆ្គង ដំណឹងល្អក្លែងក្លាយដែលអ្នកទាំងនោះនឹងត្រូវទទួលទោសអស់កល្បជានិច្ច (កាឡាទី ១:៩, ២កូរិន. ១១:៤)។